# វត្តគិរីវង្សាបុប្ផារាម

# WAT KIRY VONGSA BOPHARAM

100A Cave Hill Road, Leverett, MA 01054-9728 U.S.A.
Phones: 413.367.0280, 978.758.0286, 978.935.3287

អាស្រមសមាធិសន្តិភាព
THE PEACE MEDITATION CENTER


## <u>សេចក្តីប្រកាសព័ត៌មាន</u>

*ថ្ងៃទី០៦ ខែធ្នូ ព.ស.២៥៥៦ គ.ស.២០១២* *ទីក្រុងឡេវើរ៉េត រដ្ឋម៉ាសាឈូសិត្តស៍*

វត្តគិរីវង្សាបុប្ផារាម មានកិត្តិយស សូមទូលប្រគេនព្រះថេរានុត្ថេរៈគ្រប់ព្រះអង្គ និង ជម្រាបជូនលោក លោកស្រី លោកតា លោកយាយ ឧបាសក ឧបាសិកា សីលវន្ត សីលវតី យោគាវចរ និងពុទ្ធបរិស័ទជ្រាបថា វត្ត បង្រៀនកម្មដ្ឋានចំនួន ១០ថ្ងៃ នឹងចាប់បើកពីថ្ងៃ ១២កើត ខែជេស្ឋ ព.ស.២៥៥៧ ត្រូវនឹងថ្ងៃទី២០ ខែមិថុនា គ.ស. ២០១៣ ទៅដល់ថ្ងៃ ០៧រោច ខែជេស្ឋ ព.ស.២៥៥៧ ត្រូវនឹងថ្ងៃទី៣០ ខែមិថុនា គ.ស.២០១៣ ថ្ងៃបិទវគ្គ។

សូមទូលប្រគេនព្រះថេរានុត្ថេរៈ និង ជម្រាបសប្បុរសជនគ្រប់វ័យៈ បឋមវ័យ (វ័យក្មេង) មជ្ឈឹមវ័យ (វ័យមានគូស្រករ) បច្ឆឹមវ័យ (វ័យចាស់) ជ្រាបថា ការរៀនកម្មដ្ឋាន ប្រសិនបើមិនចេះសូត្រធម៌ក្តី មិនចេះអក្សរក្តី ឬមិនទាន់បានធ្វើសមាទានសីលក្តី ឱ្យតែចេះអង្គុយ អាចរៀនកម្មដ្ឋានបានទាំងអស់ សង្ឃភេទរៀនកម្មដ្ឋានបានដែរ។

ប្រសិនបើព្រះករុណា លោក លោកស្រី លោកតា លោកយាយ ឧបាសក ឧបាសិកា សីលវន្ត សីលវតី យោគាវចរ និងបងប្អូនមានបំណងរៀន សូមមេត្តាចុះព្រះនាម និង ឈ្មោះដាក់ក្នុងប័ណ្ណមួយសន្លឹក ដែលភ្ជាប់មកជាមួយសេចក្តីប្រកាសនេះ ហើយសូមផ្ញើមកវត្តគិរីវង្សាបុប្ផារាម តាមអាសយដ្ឋានៈ Wat Kiry Vongsa Bopharam, 100A Cave Hill Road, Leverett, MA 01054-9728 U.S.A. ឱ្យបានមុនថ្ងៃបើកវគ្គ ចំនួនពីរខែសម្រាប់សប្បុរសជននៅប្រទេស រដ្ឋ ខេត្ត និងទីក្រុងឆ្ងាយៗ មុនជាកំណត់។

សម្រាប់ការរៀនកម្មដ្ឋាន សូមមេត្តាទាក់ទងមកលេខទូរស័ព្ទៈ ៤១៣.៣៦៧.០២៨០, ៩៧៨.៧៥៨.០២៨៦, ៩៧៨.៩៣៥.៣២៨៧ ឬអ៊ីមែលៈ vipassanadhura@gmail.com ។